**ការធ្វើទុក្ខបុកម្នេញ (persecution)**

ការធ្វើទុក្ខបុកម្នេញ ត្រូវបានផ្ដល់ន័យថា ជាការដកហូតនូវសិទ្ធិសេរីភាពចម្បង (fundamental rights) ដោយចេតនា និងធ្ងន់ធ្ងរ ផ្ទុយនឹងច្បាប់អន្តរជាតិ ផ្អែកតាមហេតុផល នៃអត្តសញ្ញាណបុគ្គល ក្រុម ឬសហគម (មាត្រា ៧.២ នៃលក្ខន្តិកៈ ICC)។ ការធ្វើទុក្ខបុកម្នេញ ជាបទល្មើសមួយ នៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ (crime against humanity)។

ផ្អែកតាមវិធានទំនៀមទម្លាប់ (customary international law) មូលដ្ឋាននៃ ការធ្វើទុក្ខបុកម្នេញគឺ នយោបាយ សាសនា និងពូជ សាសន៍។ សម្រាប់ធាតុផ្សំសំភារៈ វាអាចជាទង្វើ អនុវត្តទាក់ទងនឹងបទល្មើសណាមួយ ទោះបីជាបំពាន ឬមិនបំពានច្បាប់ជាតិក្ដី។ ទង្វើទាំងនោះ មានច្រើនរាប់បញ្ចូលនូវ សកម្មភាពមានលក្ខណៈសេដ្ឋកិច្ច ឬក្នុងវិស័យតុលាការ ដែលចៅក្រម បានបំពានសិទ្ធិបុគ្គលក្នុងការទទួលបាននូវការប្រព្រឹត្តស្រ័យស្មើភាពនៃសិទ្ធិចម្បងរបស់ខ្លួន( Tadic, IT-94-1-T, 7 May 1997, S. 710)។

ទង្វើនោះ អាចជាការសម្លាប់ (murder) ការធ្វើទារុណកម្ម (torture) ការផ្ទេរដោយបង្ខំ (forced transfer) ការបំផ្លាញសម្បត្តិវប្បធម៌ (destruction of cultural property) ។ សេចក្ដីថ្លែងការណ៍សម្អប់ពូជសាសន៍ ក៏អាចត្រូវបានរាប់ជា ការធ្វើទុក្ខបុកម្នេញដែរ ប្រសិនបើមានលក្ខណៈរើសអើង (discrimination) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, 453-454)។